


# សមិទ្ធផលផ្នែកសារពើពន្ធឆ្នាំ២០១៨

## សេចក្តីសង្ខេបនៃការវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋឆ្នាំ២០១៨

ខែធ្នូ ឆ្នាំ២០១៩

រក្សាសិទ្ធិដោយ©២០១៩

រក្សាសិទ្ធិគ្រប់យ៉ាង។ ការស្រាវជ្រាវនេះ ឬផ្នែកណាខ្លះនៃរបាយការណ៍នេះមិនអាចយកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាត្តិពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

បោះពុម្ពដោយព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
វិមានរដ្ឋចំការមន វិថីព្រះនរោត្តម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ https://senate.gov.kh/

# សមិទ្ធផលផ្នែកសារពើពន្ធឆ្នាំ២០១៨

## អំពីរបាយការណ៍

របាយការណ៍ស្តីពី សមិទ្ធផលនៃសារពើពន្ធឆ្នាំ២០១៨ រៀបរាងឡើងដោយមន្ត្រីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍មួយ នៃកម្មវិធីបណ្តុះបណ្តាល និងសម្រាប់ជាព័ត៌មានជំនួយស្មារតីជូនគណៈកម្មការព្រឹទ្ធសភា ទាក់ទងនឹងការអនុវត្តថវិកាជាតិ។ របាយការណ៍នេះគឺយោងទៅលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ (ដែលនៅក្នុងឯកសារនេះនឹងប្រើពាក្យថា *សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*) ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា មុនកិច្ចប្រជុំសភា និងទិន្នន័យប្រចាំខែ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការពិនិត្យឡើងវិញទៅលើការអនុវត្តថវិកាដែលធ្វើឡើងប្រចាំឆ្នាំដោយសភា អាចជំរុញដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលអោយកាន់តែប្រសើរ ដើម្បីបង្កើននូវសមិទ្ធផលសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងពង្រឹងអភិបាលកិច្ចល្អ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានមន្ត្រីស្រាវជ្រាវមួយក្រុម ដែលការទទួលបាននូវទិន្នន័យផ្នែកសេដ្ឋកិច្ច និងសារពើពន្ធជាក់ស្តែង និងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល នៅមានកម្រិតនៅឡើយ។ ហេតុដូចនេះ សម្រាប់ការធ្វើផែនការ សមាជិកសភា និងអ្នកពាក់ព័ន្ធដទៃទៀត គួរបន្តផ្អែកលើព័ត៌មានផ្លូវការរបស់រាជរដ្ឋាភិបាល។ របាយការណ៍នេះមានគោលបំណង ត្រឹមផ្តល់ជូននូវព័ត៌មានទូទៅរួមមួយទៅលើសូចនាករសារពើពន្ធ ដែលអាចជួយដល់សមាជិកសភាក្នុងការកំណត់នូវរាល់ការវិវត្តនានា ដែលត្រូវការការយកចិត្តទុកដាក់។

## ចំនុចសំខាន់ៗមួយចំនួន

- **ចំណូលលើសពីផែនការ៖** យោងតាមសេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨ ការអនុវត្តថវិកាចំណូលក្នុងប្រទេសជាក់ស្តែងសម្រេចបាន ២០ ៣៤១ ប៊ីលានរៀល ក្នុងឆ្នាំ២០១៨ ដែលមានការកើនឡើង ១៩ ភាគរយ ធៀបនឹងឆ្នាំ២០១៧ និងលើសផែនការចំនួន ១៥ ភាគរយ។ ចំណូលសារពើពន្ធ បានបន្តដំណើរការដ៏រឹងមាំក្នុងឆ្នាំ២០១៨ ជាមួយនឹងកំណើន ១៩ ភាគរយ។ ការកើនឡើងនេះគឺមកពីការកើនឡើងចំណូលពីអាករពិសេស និងពន្ធលើការនាំចូល ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃចំណាយរបស់អ្នកប្រើប្រាស់ និងកិច្ចខិតខំប្រឹងប្រែងកៀរគរចំណូល។
- **ការចំណាយត្រូវបានអនុវត្តតាមផែនការ៖** ការអនុវត្តចំណាយថវិកាក្នុងឆ្នាំ២០១៨មានចំនួន ២២ ៥៥១ ប៊ីលានរៀល កើនឡើង ១៣ ភាគរយធៀបនឹងឆ្នាំ២០១៧ ប៉ុន្តែការអនុវត្តនេះនៅទាបជាងផែនការចំនួន ៤ ភាគរយ។ ចំណាយថវិកាចរន្តកើនឡើង ១៣ ភាគរយ ខណៈដែលចំណាយមូលធនបានកើនឡើង ១២ ភាគរយ។

- **អតិរេកបច្ចុប្បន្នមានការកើនឡើង៖** ដោយមិនគិតរួមបញ្ចូលនូវថវិកាមូលធនវិនិយោគដុល ការអនុវត្តថវិកាចរន្តមានអតិរេកចំនួន ៥ ១៧៤ ប៊ីលានរៀល កើនឡើង ៣៩ ភាគរយ ធៀបនឹងឆ្នាំ២០១៧ និងមានការកើនឡើងបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៥។
- **ឱនភាពថវិការួមមានលក្ខណៈស្របទៅនឹងស្ថានភាពថ្មីៗ៖** ដោយគិតរួមបញ្ចូលថវិកាមូលធនវិនិយោគដុល ការអនុវត្តថវិកាមានឱនភាពសរុបចំនួន ២ ២១០ ប៊ីលានរៀល ដែលធ្លាក់ចុះប្រមាណ ២៤ ភាគរយ ធៀបនឹងឆ្នាំ២០១៧ ដែលមានឱនភាពថវិកាសរុបចំនួន ២ ៩០៧ ប៊ីលានរៀល។

រូបភាពទី១៖តុល្យភាពថវិកាមានលក្ខណៈស្របទៅនឹងស្ថានភាពថ្មីៗ (គិតជាប៊ីលានរៀល)




*ប្រភព៖ សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨[1]*

## ការអនុវត្តចំណូលថវិកា

រាជរដ្ឋាភិបាលកម្ពុជាបានរកប្រាក់ចំណូលក្នុងប្រទេសសរុប ចំនួន ២០ ៣៤១ ប៊ីលានរៀល ក្នុងឆ្នាំ២០១៨ កើនឡើង១៩ ភាគរយ ពីឆ្នាំ២០១៧ (តារាងទី១)។

ចំណូលថវិកាចរន្តមានចំនួន ២០ ១៤៧ ប៊ីលានរៀល ក្នុងឆ្នាំ ២០១៨ កើនឡើង ១៩ ភាគរយ។ ចំណូលពន្ធមានការកើនឡើង១៩ ភាគរយ (ដោយសារអាករពិសេសកើនឡើង៣៥ភាគរយ ខណៈដែលចំណូលមិនមែនសារពើពន្ធកើនឡើង ១៧ភាគរយ)។

បើធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៨ ចំណូលក្នុងប្រទេសសរុបមានការកើនឡើង ១៥ ភាគរយ ខ្ពស់ជាងផែនការថវិកា។ កត្តាចម្បងនៃភាពខុសគ្នានេះគឺដោយសារចំណូលពីពន្ធប្រយោលមានលទ្ធផលខ្ពស់ គឺលើស១៥ ភាគរយ និងអាករពិសេស លើស ២៥ ភាគរយ ។

ចំណូលពន្ធក្នុងស្រុកផ្សេងៗទៀត បើទោះបីជាមានចំណែកតិចក៏ដោយ ក៏បានអនុវត្តលើសផែនការរហូតដល់ ៧១ ភាគរយ ដែលក្នុងនោះរួមមាន៖ ពន្ធតែមប្រ៍ និងប្រាក់ទោសទណ្ឌសារពើពន្ធ។

ចំណូលមិនមែនសារពើពន្ធ មានចំនួន ១៤ ភាគរយ នៃចំណូលក្នុងប្រទេសសរុប និងបានអនុវត្តលើសផែនការ ២០ ភាគរយ ដោយសាររាជរដ្ឋាភិបាលមានការរីកចម្រើនក្នុងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង

ចំណូលមិនមែនសារពើពន្ធ ការធ្វើបញ្ជីសារពើភណ្ឌលើទ្រព្យសម្បត្តិរដ្ឋ ការលើកកម្ពស់ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ន។

តារាងទី១៖ សមាសភាពនៃចំណូលសារពើពន្ធ ឆ្នាំ ២០១៧ និង ឆ្នាំ២០១៨ (គិតជាប៊ីលានរៀល)

| | ការប្រែប្រួលធៀបនឹងឆ្នាំមុន | | | ថវិកា និងអនុវត្តន៍ ឆ្នាំ២០១៨ | | |
|---|---|---|---|---|---|---|
| | 2017 | 2018 | កំណើន | ថវិកា | អនុវត្តន៍ | ខុសគ្នា |
| **I. ចំណូលក្នុងប្រទេស** | **17,109** | **20,341** | **+19%** | **17,640** | **20,341** | **+15%** |
| ១. ចំណូលចរន្ត | 16,967 | 20,147 | +19% | 17,640 | 20,147 | +15% |
| ក. ចំណូលសារពើពន្ធ | 14,521 | 17,296 | +19% | 15,076 | 17,296 | +15% |
| ចំណូលសារពើពន្ធក្នុងស្រុក | 12,543 | 14,925 | +19% | 12,934 | 14,925 | +15% |
| ពន្ធផ្ទាល់ | 3,798 | 4,059 | +7% | 3,899 | 4,059 | +4% |
| ពន្ធប្រយោល | 4,936 | 5,729 | +16% | 4,962 | 5,729 | +15% |
| អាករពិសេស | 3,676 | 4,969 | +35% | 3,974 | 4,969 | +25% |
| ចំណូលសារពើពន្ធផ្សេងៗ | 133 | 168 | +26% | 99 | 168 | +71% |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1,977 | 2,371 | +20% | 2,142 | 2,371 | +11% |
| ពន្ធ និងអាករលើការនាំចូល | 1,931 | 2,319 | +20% | 2,096 | 2,319 | +11% |
| ពន្ធ និងអាករលើការនាំចេញ | 46 | 52 | +13% | 46 | 52 | +14% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 2,446 | 2,851 | +17% | 2,384 | 2,851 | +20% |
| ២. ចំណូលមូលធន (ចំណូលពីប្រភពផ្ទាល់) | 142 | 195 | +37% | 180 | 195 | +8% |

*ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*

## ការអនុវត្តចំណាយថវិកា

ការអនុវត្តចំណាយថវិកាសរុបរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០១៨ មានចំនួន ២២ ៥៥១ ប៊ីលានរៀល កើនឡើង ១៣ ភាគរយ ពីចំនួន ២០ ០១៦ ប៊ីលានរៀល ក្នុងឆ្នាំ ២០១៧។ ការអនុវត្តចំណាយថវិកា ឆ្នាំ ២០១៨ គឺទាបជាង ផែនការ ៣,៩ ភាគរយ។

ចំពោះការអនុវត្តចំណាយថវិកាចរន្តមានចំនួន ១៤ ៩៧២ ប៊ីលានរៀលក្នុងឆ្នាំ ២០១៨ កើនពី ១៣ ២៣៧ ប៊ីលានរៀល ក្នុងឆ្នាំ២០១៧ ពោលគឺកើនឡើង ១៣ ភាគរយ។

## ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច

ផ្នែកនេះពិនិត្យមើលកំណើននៃការចំណាយតាមចំណាត់ថ្នាក់នៃធាតុចូលផ្នែកសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល (តារាងទី២)៖

- ចំណាយបន្ទុកបុគ្គលិក ដែលមានចំនួនរហូតដល់ ៥៣ ភាគរយនៃចំណាយចរន្ត ពោលគឺកើនឡើង១៧ ភាគរយ ធៀបនឹងឆ្នាំ២០១៧ និងចំណាយលើសផែនការចំនួន ១,១ ភាគរយ។ ចំណាយបៀវត្សសម្រាប់វិស័យការពារជាតិ និងសន្តិសុខ បានកើនឡើង ១៩ភាគរយ ខណៈផ្នែករដ្ឋបាលស៊ីវិលកើនឡើង ១៦ ភាគរយ។

- ចំណាយក្រៅបន្ទុកបុគ្គលិក មានចំនួន ៤៧ ភាគរយនៃចំណាយចរន្ត មានកំណើនត្រឹម ៩ ភាគរយ ធៀបនឹងឆ្នាំ២០១៧ និងអនុវត្តបានតែ ៩៥ ភាគរយនៃចំណាយដែលបានគ្រោងទុកក្នុងឆ្នាំ ២០១៨។
- គួរកត់សម្គាល់ផងដែរ ការចំណាយលើអត្ថប្រយោជន៍សង្គម ដែលជាផ្នែកមួយនៃការចំណាយក្រៅបន្ទុកបុគ្គលិក បានអនុវត្តលើសផែនការរហូតដល់ចំនួន ៣៤ភាគរយ។ សមាជិកសភាអាចត្រូវការស្វែងរកការបំភ្លឺបន្ថែម ដើម្បីស្វែងយល់អំពីកំណើនខ្ពស់នេះ។
- ជារួម ចំណាយចរន្ត គឺអនុវត្តបាន ៩៨,២ ភាគរយ នៃថវិកាដែលបានគ្រោងទុកក្នុងឆ្នាំ២០១៨។
- ចំណាយមូលធនបានកើនឡើងពី ៦ ៧៧៩ ប៊ីលានរៀល ក្នុងឆ្នាំ២០១៧ ដល់ ៧ ៥៧៨ ប៊ីលានរៀល នៅឆ្នាំ២០១៨ ពោលគឺកើនឡើង ១២ ភាគរយ។ នៅក្នុងចំណាយមូលធន វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស បានកើនឡើងគួរឱ្យកត់សម្គាល់ ចំនួន ២៧ ភាគរយ ធៀបនឹងឆ្នាំ២០១៧ ខណៈការវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស កើនឡើងតែ ២ ភាគរយ ក្នុងរយៈពេលដូចគ្នា។ សរុបមក ការអនុវត្តចំណាយមូលធនមានចំនួន ៩២,៣ ភាគរយនៃផែនការឆ្នាំ២០១៨។

តារាងទី២: ការចំណាយថវិកាតាមចំណាត់ថ្នាក់ផ្នែកសេដ្ឋកិច្ច (គិតជាប៊ីលានរៀល)

| | ការប្រែប្រួលធៀបនឹងឆ្នាំមុន (ជាក់ស្តែង) | | | ថវិកា ធៀបនឹងអនុវត្តន៍ (២០១៨) | | |
|---|---|---|---|---|---|---|
| | 2017 | 2018 | កំណើន | ថវិកា | អនុវត្តន៍ | លើស/ខ្វះ |
| **II. ថវិកាចំណាយ** | **20,017** | **22,551** | **13%** | **23,456** | **22,551** | **-4%** |
| 1. ការចំណាយចរន្ត | 13,238 | 14,973 | 13% | 15,246 | 14,973 | -2% |
| a. បន្ទុកបុគ្គលិក | 6,839 | 8,001 | 17% | 1% | 8,001 | 1% |
| រដ្ឋបាលទូទៅ | 4,265 | 4,946 | 16% | 0% | 4,946 | 0% |
| ការពារជាតិ និងសន្តិសុខ | 2,574 | 3,055 | 19% | 2% | 3,055 | 2% |
| b. ក្រៅបន្ទុកបុគ្គលិក | 6,399 | 6,971 | 9% | 7,331 | 6,971 | -5% |
| ការទិញ | 1,408 | 1,529 | 9% | 1,550 | 1,529 | -1% |
| សេវាកម្ម | 1,582 | 1,687 | 7% | 1,743 | 1,687 | -3% |
| បន្ទុកហិរញ្ញវត្ថុ | 342 | 387 | 13% | 387 | 387 | 0% |
| អត្ថប្រយោជន៍សង្គម | 1,086 | 1,336 | 23% | 996 | 1,336 | 34% |
| ឧបត្ថម្ភធន | 1,382 | 1,350 | -2% | 1,502 | 1,350 | -10% |
| ក្រៅបន្ទុកបុគ្គលិកផ្សេងៗ | 599 | 682 | 14% | 1,153 | 682 | -41% |
| 2. ការចំណាយមូលធន | 6,779 | 7,579 | 12% | 8,210 | 7,579 | -8% |
| ហិរញ្ញប្បទានក្នុងប្រទេស | 2,560 | 3,257 | 27% | 3,663 | 3,257 | -11% |
| ហិរញ្ញប្បទានក្រៅប្រទេស (គម្រោង) | 4,219 | 4,322 | 2% | 4,547 | 4,322 | -5% |

*ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*

## ចំណាយថវិកាបែងចែកតាមមុខងារ

រាជរដ្ឋាភិបាលកម្ពុជា បែងចែកការចំណាយទៅតាមមុខងារចំនួន ០៥ (តារាងទី៣)។ ក្នុងឆ្នាំ២០១៨ ចំណែកធំបំផុតនៃចំណាយចរន្តគឺការចំណាយលើវិស័យសង្គមកិច្ច ដែលកើនឡើង ១៩ ភាគរយ ធៀបនឹងឆ្នាំ២០១៧ បន្ទាប់មកការចំណាយលើវិស័យការពារជាតិ និងសន្តិសុខ ដែលបានកើនឡើង ១៧ ភាគរយ។ វិស័យសង្គមកិច្ចនៅតែជាវិស័យអាទិភាពទីមួយរបស់រាជរដ្ឋាភិបាល ពីព្រោះវិស័យនេះផ្តោតទៅលើការអប់រំ សុខភាព យេនឌ័រ ពលកម្ម និងកិច្ចការសង្គមដ៏ទៃទៀត រួមមានអតីតយុទ្ធជន និងយុវនីតិសម្បទា។ ចំណាយមិនទាន់បែងចែក ទោះបីជាមានចំនួនតិចក៏ដោយ ក៏មានការកើនឡើងខ្លាំងរហូតដល់ ២១ ភាគរយ ធៀបនឹងឆ្នាំ២០១៧ ប៉ុន្តែអនុវត្តបានទាបជាងផែនការគួរឱ្យកត់សម្គាល់ (១ ៣៦៨ ប៊ីលានរៀល ធៀបនឹង ១ ៥៣៦ ប៊ីលានរៀល គឺខុសគ្នាចំនួន ១១ ភាគរយ)។

តារាងទី៣: ចំណាយចរន្ត បែងចែកតាមមុខងារ (គិតជាប៊ីលានរៀល)

| | ការប្រែប្រួលធៀបនឹងឆ្នាំមុន | | | | ថវិកា និងអនុវត្តន៍ ឆ្នាំ ២០១៨ | | |
|---|---|---|---|---|---|---|---|
| | ចំណែក | 2017 | 2018 | កំណើន | ថវិកា | អនុវត្តន៍ | **ខុសគ្នា** |
| I. វិស័យរដ្ឋបាលទូទៅ | 16.5% | 2,536 | 2,471 | -3% | 2,534 | 2,471 | -3% |
| II. វិស័យការពារជាតិ និងសន្តិសុខ | 26.6% | 3,405 | 3,989 | 17% | 3,903 | 3,989 | 2% |
| III. វិស័យសង្គមកិច្ច | 38.4% | 4,841 | 5,756 | 19% | 5,871 | 5,756 | -2% |
| IV. វិស័យសេដ្ឋកិច្ច | 9.3% | 1,323 | 1,387 | 5% | 1,402 | 1,387 | -1% |
| V. វិស័យផ្សេងៗ | 9.1% | 1,132 | 1,368 | 21% | 1,536 | 1,368 | -10.1% |

*ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*

## ចំណាយថវិកាតាមក្រសួង ស្ថាប័ន

តារាងទី៤ បង្ហាញនូវក្រសួងចំនួន១០ ដែលបានចំណាយលើសផែនការខ្ពស់ជាងគេ និងក្រសួងចំនួន១០ ដែលចំណាយទាបជាងផែនការខ្លាំងជាងគេ ដោយយោងលើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨ ធៀបនឹងផែនការឆ្នាំដូចគ្នា (តារាងពេញមាននៅក្នុងឧបសម្ព័ន្ធទី១)។ ក្រសួងពាណិជ្ជកម្មបានចំណាយលើសផែនការចំនួន ១៩ ភាគរយ បន្ទាប់មកគឺក្រសួងមហាផ្ទៃដែលចំណាយលើសផែនការចំនួន ១២ភាគរយ។ រដ្ឋលេខាធិការដ្ឋាននៃអាកាសចរណ៍ស៊ីវិល និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានចំណាយថវិកាច្រើនជាងផែនការចំនួន ១០ ភាគរយ។ ផ្ទុយទៅវិញ ក្រសួងរ៉ែ និងថាមពលស្ថិតនៅបាតតារាង ដោយចំណាយក្រោមផែនការ ១៧ ភាគរយ បន្ទាប់មកគឺក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានចំណាយតិចជាងផែនការរហូតដល់ទៅ ១៣ ភាគរយ។

តារាងទី៤: ក្រសួង១០ដែលចំណាយខ្ពស់ជាងគេ និងក្រសួង១០ដែលចំណាយទាបជាងគេ ធៀបនឹងផែនការ

| ចំណាយថវិកាតាមក្រសួង ស្ថាប័ន | ការប្រែប្រួលធៀបឆ្នាំមុន | | | ការអនុវត្ត និងថវិកា២០១៨ | | |
|---|---|---|---|---|---|---|
| | 2017 | 2018 | កំណើន | ថវិកា | អនុវត្តន៍ | ខុសគ្នា |
| ក្រសួងពាណិជ្ជកម្ម | 133.37 | 151.72 | 13.8% | 127.31 | 151.72 | 19% |
| ក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) | 140.10 | 182.43 | 30.2% | 163.58 | 182.43 | 12% |
| រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 58.50 | 58.33 | -0.3% | 52.84 | 58.33 | 10% |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 147.53 | 165.09 | 11.9% | 150.10 | 165.09 | 10% |
| ក្រសួងមហាផ្ទៃ (សន្តិសុខសារធារណៈ) | 1,250.63 | 1,452.21 | 16.1% | 1,398.65 | 1,452.21 | 4% |
| អង្គភាពប្រឆាំងអំពើពុករលួយ | 34.21 | 44.18 | 29.2% | 42.60 | 44.18 | 4% |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 10.64 | 11.92 | 12.0% | 11.70 | 11.92 | 2% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 797.48 | 901.78 | 13.1% | 889.04 | 901.78 | 1% |
| ព្រឹទ្ធសភា | 65.33 | 75.80 | 16.0% | 74.82 | 75.80 | 1% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 228.97 | 303.35 | 32.5% | 299.55 | 303.35 | 1% |
| ក្រសួងកិច្ចការនារី | 40.58 | 45.63 | 12.4% | 47.60 | 45.63 | -4% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 87.31 | 79.28 | -9.2% | 83.02 | 79.28 | -5% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 211.26 | 232.35 | 10.0% | 245.01 | 232.35 | -5% |
| អាជ្ញាធរសវនកម្មជាតិ | 10.77 | 13.05 | 21.2% | 13.81 | 13.05 | -5% |
| ក្រសួងព័ត៌មាន | 71.09 | 73.98 | 4.1% | 78.29 | 73.98 | -6% |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 44.30 | 50.06 | 13.0% | 53.20 | 50.06 | -6% |
| ក្រសួងយុត្តិធម៌ | 109.99 | 128.74 | 17.0% | 138.32 | 128.74 | -7% |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 155.96 | 186.18 | 19.4% | 212.80 | 186.18 | -13% |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) | 13.07 | 13.14 | 0.5% | 15.04 | 13.14 | -13% |
| ក្រសួងរ៉ែ និងថាមពល | 49.11 | 41.56 | -15.4% | 50.00 | 41.56 | -17% |

*ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*

# តុល្យភាពថវិកា

រាជរដ្ឋាភិបាលកម្ពុជាបានដំណើរការឱនភាពសរុបថវិកាក្នុងឆ្នាំ២០១៨ តិចជាងឱនភាពសរុបថវិកាឆ្នាំ២០១៧ និងតិចជាងការរំពឹងទុកក្នុងឆ្នាំ២០១៨ (តារាងទី៥)។

ថវិកាចរន្តក្នុងឆ្នាំ២០១៨ មានអតិរេកចរន្តចំនួន ៥ ១៧៤ ប៊ីលានរៀល ដែលមានការកើនឡើង ៣៩ ភាគរយ ធៀបនឹងឆ្នាំ២០១៧ នឹងលើសផែនការរហូតដល់ ចំនួន ១៣៣ ភាគរយ។

តារាងទី៥៖តុល្យភាពថវិកា (គិតជាប៊ីលានរៀល)

| | ការប្រែប្រួលធៀបនឹងឆ្នាំមុន | | | ការអនុវត្ត និងថវិកាឆ្នាំ ២០១៨ | |
|---|---|---|---|---|---|
| | 2017 | 2018 | កំណើន (%) | អនុវត្តន៍ | ថវិកា |
| ថវិកាចរន្តឱនភាព/អតិរេក | 3,730 | 5,174 | +39% | 5,174 | 2,214 |
| សរុបថវិកា ឱនភាព/អតិរេក | -2,907 | -2,210 | -24% | -2,210 | -5,816 |

*ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ ២០១៧-២០១៨*

## ការផ្តល់ហិរញ្ញប្បទាន

រាល់សូចនាករនៃនិរន្តភាពបំណុលរបស់កម្ពុជាទាំងអស់ ស្ថិតនៅក្រោមកម្រិតហានិភ័យនៃក្របខ័ណ្ឌនិរន្តភាពបំណុល (Debt Sustainability Framework)។

ដើម្បីផ្តល់នូវហិរញ្ញប្បទានទៅលើឱនភាព ជាពិសេសទៅលើការវិនិយោគមូលធន រាជរដ្ឋាភិបាលបានទទួលនូវជំនួយ និងប្រាក់កម្ចី។ កម្ចីក្រៅប្រទេសបានធ្លាក់ចុះបន្តិចពី ២២,៨ភាគរយ នៃផ.ស.ស. ក្នុងឆ្នាំ២០១៧ ទៅ ២១,៥ភាគរយ ក្នុងឆ្នាំ២០១៨ (តារាងទី៦)។ នៅចុងឆ្នាំ២០១៨ បំណុលសាធារណៈសរុបមានចំនួន ២១,៥ភាគរយ នៃផ.ស.ស. ខណៈរាជរដ្ឋាភិបាលកម្ពុជាពឹងផ្អែកទាំងស្រុងទៅលើបំណុលខាងក្រៅក្នុងការផ្គត់ផ្គង់ឱនភាពថវិការបស់ខ្លួន។

តារាងទី៦៖សូចនាករនិរន្តភាពនៃបំណុលសម្រាប់ឆ្នាំ ២០១៧ ដល់ ២០១៨

| សូចនាករ | ២០១៧ | ២០១៨ | កម្រិតអនុបាតគោល |
|---|---|---|---|
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈធៀបនឹង ផ.ស.ស. | 22.8% | 21.5% | 55% |
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងផ.ស.ស. | 22.8% | 21.5% | 40% |
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ | 30.8% | 28.4% | 180% |
| សេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ | 1.3% | 1.4% | 15% |
| សេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូល | 18% | 4.9% | 18% |

*ប្រភព: អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ឆ្នាំ២០១៧ និងឆ្នាំ២០១៨ [2]*

## ចំណុចពិភាក្សា

បញ្ហាមួយចំនួនដូចខាងក្រោម ដែលបានលេចឡើងពីលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ ២០១៨ គួរទទួលបានការយកចិត្តទុកដាក់ និងការស្វែងរកព័ត៌មានបន្ថែម ខណៈសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ កំពុងត្រូវបានពិចារណា។

- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃអាណត្តិទី៦របស់រាជរដ្ឋាភិបាល អាទិភាពចម្បងមួយក្នុងចំណោមអាទិភាពផ្សេងទៀតរបស់រាជរដ្ឋាភិបាល គឺការផ្គត់ផ្គង់អគ្គិសនី។ ដោយសារក្រសួងធនធានរ៉ែ និងថាមពល ជាអ្នកទទួលបន្ទុកជំរុញអោយការផ្គត់ផ្គង់អគ្គិសនីមានភាពប្រសើរឡើង តើជាការគួរកត់សម្គាល់ដែរឬទេ នៅពេលដែលក្រសួងនេះអនុវត្តថវិកាតិចជាងផែនការរហូតដល់ ១៧ភាគរយ?
- ព័ត៌មានដែលអាចរកបានអំពីក្រសួងដែលបានអនុវត្តថវិកាលើសផែនការនៅមានកម្រិត តើលទ្ធផលនេះជាលទ្ធផលជាក់លាក់ដោយសារកត្តាអ្វីមួយ ឬជាបញ្ហាដែលកើតឡើងជារចនាសម្ព័ន្ធ? តើសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០២០ បានធ្វើវិភាជថវិកាបន្ថែមទៀតដល់ក្រសួងទាំងនោះដែរឬទេ? ប្រសិនបើមិនបានផ្តល់បន្ថែម តើគួរមានការកែសម្រួលឬទេ?

## ឧបសម្ព័ន ១: លទ្ធផលនៃការការអនុវត្តថវិកាឆ្នាំ២០១៨ តាមក្រសួងស្ថាប័ន

| ចំណាយថវិកាតាមក្រសួង ស្ថាប័ន | ការប្រែប្រួលធៀបឆ្នាំមុន | | | ការអនុវត្ត និងថវិកា២០១៨ | | |
|---|---|---|---|---|---|---|
| | 2017 | 2018 | កំណើន | ថវិកា | ការអនុវត្ត | ខុសគ្នា |
| ក្រសួងពាណិជ្ជកម្ម | 133 | 152 | 13.8% | 127 | 152 | 19% |
| ក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) | 140 | 182 | 30.2% | 164 | 182 | 12% |
| រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល | 59 | 58 | -0.3% | 53 | 58 | 10% |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 148 | 165 | 11.9% | 150 | 165 | 10% |
| ក្រសួងមហាផ្ទៃ (សន្តិសុខសារធារណៈ) | 1,251 | 1,452 | 16.1% | 1,399 | 1,452 | 4% |
| អង្គភាពប្រឆាំងអំពើពុករលួយ | 34 | 44 | 29.2% | 43 | 44 | 4% |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 11 | 12 | 12.0% | 12 | 12 | 2% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 797 | 902 | 13.1% | 889 | 902 | 1% |
| ព្រឹទ្ធសភា | 65 | 76 | 16.0% | 75 | 76 | 1% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 229 | 303 | 32.5% | 300 | 303 | 1% |
| ក្រសួងការពារជាតិ | 1,904 | 2,226 | 16.9% | 2,203 | 2,226 | 1% |
| ក្រសួងធនធានទឹក និងឧត្តុនិយម | 116 | 131 | 13.3% | 131 | 131 | 0% |
| រដ្ឋសភា | 156 | 181 | 15.9% | 181 | 181 | 0% |
| ក្រសួងមុខងារសាធារណៈ | 43 | 51 | 18.9% | 51 | 51 | 0% |
| ក្រសួងបរិស្ថាន | 68 | 87 | 28.0% | 87 | 87 | 0% |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 118 | 126 | 6.2% | 126 | 126 | -1% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 155 | 168 | 8.1% | 169 | 168 | -1% |
| ព្រះបរមរាជវាំង | 100 | 96 | -3.6% | 98 | 96 | -1% |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 142 | 227 | 60.1% | 233 | 227 | -2% |
| ក្រសួងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា | 34 | 38 | 12.0% | 39 | 38 | -3% |
| ក្រសួងទេសចរណ៍ | 82 | 89 | 9.0% | 92 | 89 | -3% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 921 | 806 | -12.5% | 828 | 806 | -3% |
| ក្រសួងសុខាភិបាល | 1,177 | 1,379 | 17.2% | 1,419 | 1,379 | -3% |
| ក្រសួងអប់រំ យុវជន និងកីឡា | 2,261 | 2,675 | 18.3% | 2,753 | 2,675 | -3% |
| ក្រសួងធម្មការ និងសាសនា | 54 | 63 | 16.2% | 65 | 63 | -3% |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 387 | 386 | -0.3% | 399 | 386 | -3% |
| ក្រសួងផែនការ | 66 | 77 | 17.4% | 80 | 77 | -4% |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 661 | 587 | -11.2% | 610 | 587 | -4% |
| ក្រសួងកិច្ចការនារី | 41 | 46 | 12.4% | 48 | 46 | -4% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 87 | 79 | -9.2% | 83 | 79 | -5% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 211 | 232 | 10.0% | 245 | 232 | -5% |
| អាជ្ញាធរសវនកម្មជាតិ | 11 | 13 | 21.2% | 14 | 13 | -5% |
| ក្រសួងព័ត៌មាន | 71 | 74 | 4.1% | 78 | 74 | -6% |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 44 | 50 | 13.0% | 53 | 50 | -6% |
| ក្រសួងយុត្តិធម៌ | 110 | 129 | 17.0% | 138 | 129 | -7% |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 156 | 186 | 19.4% | 213 | 186 | -13% |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) | 13 | 13 | 0.5% | 15 | 13 | -13% |
| ក្រសួងរ៉ែ និងថាមពល | 49 | 42 | -15.4% | 50 | 42 | -17% |

*ប្រភព: ប្រភព: សេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៨*

## ឯកសារយោង

1. MoEF, (2015-2018). *Law of national budget implementation*. Phnom Penh, Cambodia: MoEF, [Accessed 20/11/2019].
2. MoEF, (2017-2018). *Cambodia Public Debt Statistical Bulletin*. Phnom Penh, Cambodia: MoEF, Available at: https://www.mef.gov.kh/documents/shares/publication/public-debt-bulletin/Cambodia-Public-Debt-Statistical-Bulletin-Volume-8-2019.pdf [Accessed 20/11/2019].

1. MoEF, (2015-2018). *Law of national budget implementation*. Phnom Penh, Cambodia: MoEF,  [Accessed 20/11/2019].
2. MoEF, (2017-2018). *Law of national budget implementation*. Phnom Penh, Cambodia: MoEF,,  [Accessed 20/11/2019].
3. MoEF, (2018). *Law of National Budget*. Phnom Penh, Cambodia: MoEF,,  [Accessed 20/11/2019].
4. MoEF, (2017-2018). *Cambodia Public Debt Statistical Bulletin*. Phnom Penh, Cambodia: MoEF, Available at: https://www.mef.gov.kh/documents/shares/publication/public-debt-bulletin/Cambodia-Public-Debt-Statistical-Bulletin-Volume-8-2019.pdf [Accessed 20/11/2019].